## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៤

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# សេចក្តីប្រកាសព័ត៌មាន
## សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រ សម្រាប់ការរៀបចំតាក់តែងផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) ដំណាក់កាលទី២ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំសិក្ខាសាលារយៈពេល ១ថ្ងៃ នៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំពេញ វេលាម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៥:៣០ ល្ងាច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ខ៊ាន់ ចំរើន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រតិបត្តិនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។

សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រសម្រាប់ការរៀបចំតាក់តែងផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) ដំណាក់កាលទី២ ធ្វើឡើងដើម្បីពិភាក្សា និងផ្តល់យោបល់ ដើម្បីអោយការអនុវត្ត ផអ៣ ដំណាក់កាលទី២ ឆ្នាំ២០១៥-២០១៧ អោយសម្រេចបាននូវសមិទ្ធផលរំពឹងទុកទាំង៥ រួមមាន÷

- រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះ

ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំបញ្ចប់ និង/ឬពិនិត្យឡើងវិញដើម្បីធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលខុសត្រូវក្នុងការផ្តល់សេវានានា
- រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលនៅកៀកនឹងប្រជាពលរដ្ឋ ត្រូវបានផ្តល់លទ្ធភាព និងគាំទ្រដោយក្រសួង ស្ថាប័ន ថ្នាក់រដ្ឋបាលកម្រិតផ្សេងទៀត ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- ការសម្រេចនានារបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានផ្តល់ធនធានសមស្របដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពបំពេញតួនាទីរបស់ខ្លួន ប្រកបដោយគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍមូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ
- ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ត្រូវបានលើកកម្ពស់ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធ្វើឲ្យមានការផ្លាស់ប្តូរ ។

ផែនការអនុវត្តពន្លាំដំបូង (ផអ៣) ដែលជាកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ នឹងត្រូវបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៤ ខាងមុខ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី ដែលជាអ្នកសារព័ត៌មានទាំងអស់ចូលរួមយកព័ត៌មាន តាមកាលបរិច្ឆេទ និងពេលវេលាខាងលើ។

*ព័ត៌មានបន្ថែម សូមទាក់ទង÷*

លោក ជេដ្ឋ គឹមជុង ប្រធានការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

នៃលេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈលេខទូរស័ព្ទ ០១២ ៧៥៨ ៥២០

ឬ E-mail: kimchung@ncdd.gov.kh, website: www.ncdd.gov.kh